BUSINESS BANKING



# ខ និងលក្ខខណ្ឌ សម្រាប់ពាណិជ្ជករ

BRED BANK CAMBODIA

The smarter way to bank.

*Version 1.1_0326*

# មាតិកា


1. **ប្រការ 1 ៖ លក្ខណៈទូទៅ** ........ 4

  1.1 និយមន័យ ........ 4

  1.2 គោលបំណងនៃខចែង និងលក្ខខណ្ឌទាំងនេះ ........ 6

2. **ប្រការ 2 ៖ អំពីប្រព័ន្ធ** ........ 6

3. **ប្រការ 3 ៖ កាតព្វកិច្ចរបស់អ្នកទទួល** ........ 6

  3.1 កាតព្វកិច្ចទូទៅ ........ 6

  3.2 កាតព្វកិច្ចជាក់លាក់ចំពោះធនាគារ ........ 7

  3.3 កាតព្វកិច្ចទាក់ទងនឹងអ្នកប្រើប្រាស់ **KHQR** ........ 8

  3.4 កាតព្វកិច្ចផ្សេងទៀត ........ 9

4. **ប្រការ 4 ៖ ភារកិច្ចរបស់ធនាគារ** ........ 9

5. **ប្រការ 5 ៖ ការធានានៃការទូទាត់** ........ 9

6. **ប្រការ 6 ៖ នីតិវិធីសុវត្ថិភាព** ........ 9

  6.1 ប្រតិបត្តិការគ្មានសុពលភាព ........ 10

  6.2 ប្រតិបត្តិការដែលមិនអាចទទួលយកបាន ........ 10

  6.3 ការដោះស្រាយវិវាទ ........ 10

7. **ប្រការ 7 ៖ លក្ខខណ្ឌប្រតិបត្តិការដែលពាក់ព័ន្ធ** ........ 11

  7.1 បណ្តឹងតវ៉ា និងការទាមទារ ........ 11

8. **ប្រការ 8 ៖ ការកែប្រែខចែង និងលក្ខខណ្ឌនៃកិច្ចសន្យា** ........ 11

9. **ប្រការ 9 ៖ ការបញ្ចប់ខចែង និងលក្ខខណ្ឌហ្វាស៊ីលីធីពាណិជ្ជករ** ........ 11

10. **ប្រការ 10 ៖ ការផ្អាកដំណើការ ឬការលុបចោលសមាជិកភាព** ........ 12

11. **ប្រការ 11 ៖ ការមិនលះបង់សិទ្ធិ** ........ 12

12. **ប្រការ 12 ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងការប្រើប្រាស់ម៉ាស៊ីនទូទាត់** ........ 13

  12.1 ការដំឡើងម៉ាស៊ីនទូទាត់ ........ 13

  12.2 កម្មសិទ្ធិម៉ាស៊ីនទូទាត់ ........ 13

  12.3 ការធានារ៉ាប់រង ........ 13

  12.4 ការប្រើប្រាស់ និងការថែទាំម៉ាស៊ីនទូទាត់ និងឧបករណ៍ដែលធនាគារបានផ្តល់ជូន ........ 13

  12.5 ការផ្លាស់ប្តូរម៉ាស៊ីនទូទាត់ និងឧបករណ៍ធនាគារ ........ 14

  12.6 ការប្រគល់ត្រឡប់មកវិញនូវម៉ាស៊ីនទូទាត់ ឬឧបករណ៍ ........ 14

  12.7 ការខូចខាត មិនដំណើរការ ........ 14

13. **ប្រការ 13 ៖ គណនីថ្លៃសេវា និងគណនីទូទាត់** ........ 14

  13.1 គណនីថ្លៃសេវារបស់ពាណិជ្ជករ ........ 14

  13.2 សិទ្ធិអំណាចក្នុងការប្រើប្រាស់គណនីថ្លៃសេវារបស់ពាណិជ្ជករ ........ 14

  13.3 សិទ្ធិអំណាចក្នុងការប្រើប្រាស់គណនីទូទាត់របស់ពាណិជ្ជករ ........ 15

  13.4 សិទ្ធិកាត់ទុក ........ 15

  13.5 សិទ្ធិដកប្រាក់ចេញពីគណនីរបស់ពាណិជ្ជករ ........ 15

14. **ប្រការ 14 ៖ ការធានា** ........ 15

15. **ប្រការ 15 ៖ ការធានាការពាររបស់ពាណិជ្ជករ** ........ 15

16. **ប្រការ 16 ៖ ការបដិសេធ** ........ 16

17. **ប្រការ 17 ៖ ព័ត៌មានសម្ងាត់** ........ 16

  17.1 កាតព្វកិច្ចរក្សាការសម្ងាត់ទូទៅ ........ 16

  17.2 ករណីលើកលែង ........ 16

  17.3 ការប្រគល់ព័ត៌មានសម្ងាត់ត្រលប់មកវិញ ........ 17

  17.4 ការបន្តមានសុពលភាពនៃកាតព្វកិច្ច ........ 17

18. **ច្បាប់គ្រប់គ្រង និងដែនយុត្តាធិការ** ........ 17

  18.1 ច្បាប់គ្រប់គ្រង ........ 17

  18.2 ការដាក់ពាក្យប្តឹងទៅតុលាការមានសមត្ថកិច្ច ........ 17

19. **ហត្ថលេខា** ........ 17

20. **សេចក្តីសម្រេចជាស្ថាពរ** ........ 17

21. **ភាសា** ........ 17

# 1. ប្រការ 1 ៖ លក្ខណៈទូទៅ

## 1.1 និយមន័យ

**ពាណិជ្ជករ** ៖ មានន័យថា មិនសំដៅតែលើពាណិជ្ជករប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅដល់អ្នកផ្តល់សេវាបុគ្គលស្វ័យនិយោជន៍ជាដើម ដែលអាចនឹងប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក ហើយព្រមទាំងរាល់អាជីវកម្មលក់ ឬជួលទំនិញ ឬផ្តល់សេវាកម្ម។ ប្រសិនបើមានកម្មសិទ្ធិករ ឬនាយកលើសពីម្នាក់ “ពាណិជ្ជករ”គឺសំដៅលើម្ចាស់ ឬនាយកដាច់ដោយឡែក និងជារួមផងដែរ។ “ពាណិជ្ជករ” គិតរួមបញ្ចូលទាំងអ្នកដែលត្រូវបានស្នងតំណែង និងអ្នកដែលត្រូវបានចាត់តាំងផងដែរ។

**ប្រតិបត្តិការ KHQR ដែលទទួលយកបាន** ៖ មានន័យថា ប្រតិបត្តិការ KHQR ណាមួយក្រៅពីប្រតិបត្តិការទាំងឡាយដែលបានរៀបរាប់នៅក្នុងប្រការ 6.2 គឺមិនអាចទទួលយកបានទេ។

**ប្រតិបត្តិការដែលបានធ្វើឡើង** ៖ ប្រតិបត្តិការ KHQR ដែលបានធ្វើឡើងដោយអ្នកប្រើប្រាស់ KHQR ស្ថិតនៅកន្លែងអាជីវកម្មរបស់ពាណិជ្ជករ។

**មន្ត្រីដែលមានសិទ្ធិ** ៖ មានន័យថាមន្ត្រី បុគ្គលិក ភ្នាក់ងារ ឬអ្នកបម្រើការណាម្នាក់របស់ធនាគារ។

**ថ្ងៃបើកដំណើរការរបស់ធនាគារ** ៖ មានន័យថាថ្ងៃណាមួយដែលធនាគារបើកដំណើរអាជីវកម្មជូនសាធារណជន ប៉ុន្តែមិនរាប់បញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យជាតិណាមួយក្នុងប្រទេសកម្ពុជាឡើយ។

**KHQR** ៖ សំដៅលើប្រព័ន្ធទូទាត់អេឡិចត្រូនិកតាមពេលវេលាជាក់ស្តែង ដែលមានមុខងារនេះ។

**វិធាន និងនីតិវិធីបាគង** ៖ មានគោលបំណងកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធបាគង ដើម្បីធានាចីរភាព សុវត្ថិភាព និងស្ថិរភាពនៃប្រព័ន្ធទូទាត់ និងដើម្បីការពារប្រយោជន៍របស់អតិថិជន។ ច្បាប់ KHQR គឺដើម្បីគ្រប់គ្រងប្រតិបត្តិការរបស់ប្រព័ន្ធបាគង ឱ្យបានរលូន កំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធ និងគោលការណ៍ណែនាំយ៉ាងម៉ត់ចត់សម្រាប់ប្រព័ន្ធបាគង។

**ប្រតិបត្តិការ KHQR** ៖ មានន័យថាប្រតិបត្តិការលក់ ឬទូទាត់សងណាមួយរវាងពាណិជ្ជករ និងអ្នកប្រើប្រាស់ KHQR ទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ និង/ឬសេវាកម្មជូនដល់អ្នកប្រើប្រាស់ KHQR ដោយប្រើគណនី KHQR។

**អ្នកប្រើប្រាស់ KHQR** ៖ មានន័យថាជាបុគ្គលដែលទទួលបានសិទ្ធិប្រើប្រាស់ និងស្តេនទូទាត់ពីប្រព័ន្ធ បាគង។

**ព័ត៌មានសម្ងាត់** ៖ មិនរាប់បញ្ចូលទាំងព័ត៌មាន ឬសម្ភារៈដែល៖ (ក) ស្ថិតនៅក្នុងប្រភពសាធារណៈ (ក្រៅពីកើតឡើងដោយសារការបំពានខចែង និងលក្ខខណ្ឌទាំងនេះ) ឬ (ខ) ត្រូវបានបង្កើតឡើងដោយឯករាជ្យ រកឃើញ ឬដឹងដោយខ្លួនអ្នកផ្ទាល់។

**ទិន្នន័យប្រព័ន្ធអ៊ីនធើណិត** ៖ រួមបញ្ចូលទាំងព័ត៌មាន ឬមតិយោបល់ (រួមទាំងព័ត៌មាន ឬ មតិយោបល់ដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋានទិន្នន័យ) ទោះជាពិត ឬមិនពិត និងទោះត្រូវបានកត់ត្រា ឬមិនបានកត់ត្រានៅក្នុងទម្រង់ឯកសារអំពីបុគ្គលដែលមានអត្តសញ្ញាណច្បាស់លាស់ ឬដែលអាចបញ្ជាក់បានដោយសមហេតុផលពីព័ត៌មាន ឬមតិយោបល់ ដែលពាណិជ្ជករឬធនាគារបានទទួលពីប្រភពណាមួយ ដែលជាលទ្ធផលមកពីការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចក្រោមខ និងលក្ខខណ្ឌទាំងនេះ។

**បង្កាន់ដៃនៃការលក់** ៖ គឺជាបង្កាន់ដៃដែលចេញដោយម៉ាស៊ីនបោះពុម្ពនៅពេលមានប្រតិបត្តិការលក់ ឬដែលត្រូវបានដំណើរការតាមរយៈស្កានីយ។



**ឧបករណ៍** ៖ មានន័យថា បញ្ជរ ម៉ាស៊ីនបោះពុម្ព សម្ភារការិយាល័យប្រើប្រាស់សម្រាប់ការបោះពុម្ពកំណត់ត្រាប្រតិបត្តិការ និងសម្ភារការិយាល័យ សៀវភៅណែនាំ រូបបិទ ផ្សេងទៀត (និងសម្ភារសម្រាប់ផ្សព្វផ្សាយផ្សេងទៀត) និងវត្ថុណាមួយផ្សេងទៀតដែលធនាគារអាចផ្គត់ផ្គង់ដល់ពាណិជ្ជករនៅក្នុង ឬទាក់ទងនឹងខចែង និងលក្ខណ្ឌទាំងនេះ។

**កម្រៃសេវាគណនី** ៖ គឺជាគណនីរបស់ពាណិជ្ជករដែលរក្សាទុកដោយធនាគារ ស្ថិតនៅក្រោមឈ្មោះរបស់ពាណិជ្ជករ សម្រាប់ចំនួនទឹកប្រាក់ត្រូវទូទាត់ដោយធនាគារ ឬពាណិជ្ជករដែលមានឈ្មោះនៅក្នុងឯកសារពាណិជ្ជករអាចនឹងត្រូវបានកាត់ចេញ ឬបូកបន្ថែម។

**ច្បាប់** ៖ មានន័យថាច្បាប់ ឬបទប្បញ្ញត្តិ (រួមបញ្ចូលទាំងគោលនយោបាយ ការបង្គាប់ ឬ គោលការណ៍ណែនាំ) ទោះជាមាន ឬគ្មានសុពលភាពជាច្បាប់ ប៉ុន្តែត្រូវអនុលោមយោងតាមការអនុវត្តរបស់ពាណិជ្ជករដែលពាក់ព័ន្ធ។

**ឯកសារសម្រាប់ពាណិជ្ជករ** ៖ មានន័យថា ឯកសារ និងការណែនាំផ្សេងទៀតដែលបានយោងនៅក្នុងប្រការ 3.1 និងដូចដែលបានកែប្រែនៅពេលណាមួយ។

**ពាក្យស្នើសុំរបស់ពាណិជ្ជករ** ៖ មានន័យថា ពាក្យស្នើសុំរបស់ពាណិជ្ជករដើម្បីប្រើប្រាស់សេវាពាណិជ្ជករ ដែលជាកម្មវត្ថុនៃខចែង និងលក្ខខណ្ឌទាំងនេះ ដែលមានដូចជាកម្រៃសេវាផ្សេងៗដែលពាណិជ្ជករត្រូវទូទាត់ស្ថិតក្រោមខចែង និងលក្ខខណ្ឌទាំងនេះ។

**ការណែនាំលើប្រតិបត្តិការ** ៖ មានន័យថាការណែនាំលើប្រតិបត្តិការសម្រាប់ពាណិជ្ជករនីមួយៗ (និងការកែប្រែនីមួយៗទៅលើការណែនាំនោះ) ដែលចេញដោយធនាគារជូនដល់ពាណិជ្ជករពីពេលមួយទៅពេលមួយ។

**សេវាពាណិជ្ជករ** ៖ មានន័យថា សេវាដែលបានចែងក្នុងប្រការ 2។

**របាយការណ៍ពាណិជ្ជករ** ៖ មានន័យថា របាយការណ៍ដែលធនាគារផ្តល់ជូនពាណិជ្ជករ ដែលបង្ហាញពីចំនួនទឹកប្រាក់របស់ប្រតិបត្តិការដោយប្រើ KHQR ទាំងអស់ដែលពាណិជ្ជករបានបញ្ចូល នៅពេលដែលអ្នកប្រើប្រាស់ KHQR រួមជាមួយនឹងព័ត៌មានលម្អិតនៃកម្រៃសេវានានា។

**ធនាគារ** ៖ មានន័យថា ធនាគារ ប្រេដ ប៉ែង (ខេមបូឌា) ភីអិលស៊ី

**គណនីទូទាត់** ៖ គឺជាគណនីរបស់ពាណិជ្ជករជាមួយធនាគារ ដែលដាក់ឈ្មោះរបស់ពាណិជ្ជករដែលធនាគារត្រូវទូទាត់ទឹកប្រាក់ជូន ឬដែលពាណិជ្ជករដែលមានឈ្មោះនៅក្នុងឯកសារពាណិជ្ជករអាចដាក់ ឬដកប្រាក់បាន។

**កំណត់ត្រាប្រតិបត្តិការ** ៖ មានន័យថា បង្កាន់ដៃលក់អេឡិចត្រូនិច ឬ ការជូនដំណឹងផ្សេងទៀតដែលអនុម័តដោយធនាគារ។

**ម៉ាស៊ីនទូទាត់ប្រាក់** ៖ មានន័យថា ឧបករណ៍អេឡិចត្រូនិកដែលធនាគារបានយល់ព្រម ឬក្រោយមកបានយល់ព្រមផ្តល់ជូនពាណិជ្ជករ ឬផ្តល់សិទ្ធិឱ្យពាណិជ្ជករប្រើប្រាស់ដើម្បីទទួលបានការអនុញ្ញាត និងធ្វើប្រតិបត្តិការដោយប្រើ KHQR តាមប្រព័ន្ធអ៊ីនធើណិត ។

### 1.2 គោលបំណងនៃខចែង និងលក្ខខណ្ឌទាំងនេះ

នៅក្នុងខចែង និងលក្ខខណ្ឌទាំងនេះ លើកលែងតែមានការបង្ហាញពីចេតនាផ្ទុយពីនេះ

1. ជាសេចក្តីយោងដល់ខចែង និងលក្ខខណ្ឌទាំងនេះ ឬលិខិតុបករណ៍ផ្សេងណាមួយដែលរាប់បញ្ចូលទាំងខចែង និងលក្ខខណ្ឌ ឬលិខិតុបករណ៍ដែលត្រូវបានផ្លាស់ប្តូរ ឬកែប្រែ ឬជំនួស។
2. ជាសេចក្តីយោងដល់លក្ខខន្តិកៈ បទបញ្ជា ក្រម ឬច្បាប់ផ្សេងទៀត គឺរាប់បញ្ចូលទាំងបទប្បញ្ញត្តិ និងលិខិតុបករណ៍ពាក់ព័ន្ធផ្សេងទៀត និងសំណៅរួមបញ្ចូលគ្នា សំណៅវិសោធនកម្ម សំណៅអនុម័តឡើងវិញ ឬសំណៅដែលបានផ្លាស់ប្តូរជំនួសទៅលើឯកសារទាំងនេះ។
3. នាមឯកវចនៈ គឺរាប់បញ្ចូលទាំងនាមពហុវចនៈ ហើយនាមពហុវចនៈក៏រាប់បញ្ចូលទាំងនាមឯកវចនៈផងដែរ។
4. ពាក្យថា "បុគ្គល" គឺរាប់បញ្ចូលទាំងក្រុមហ៊ុន ស្ថាប័ននិតិបុគ្គល សមាគមដែលមិនមែននិតិបុគ្គល ឬអាជ្ញាធរ។
5. ការព្រមព្រៀង ការអះអាង ឬការធានា ចំពោះបុគ្គលចាប់ពីពីរនាក់ឡើងទៅ គឺសម្រាប់ជាប្រយោជន៍ដល់បុគ្គទាំងអស់រួមគ្នា និងដាច់ដោយឡែកពីគ្នា។
6. ការព្រមព្រៀង ការអះអាង ឬការធានា ពីសំណាក់បុគ្គលចាប់ពីពីរនាក់ឡើងទៅ គឺភ្ជាប់កាតព្វកិច្ចទៅលើបុគ្គទាំងអស់រួមគ្នា និងដាច់ដោយឡែកពីគ្នា។
7. សេចក្តីយោងដល់ពាក្យគណនេយ្យណាមួយនឹងត្រូវបកស្រាយដោយអនុលោមតាមស្តង់ដាគណនេយ្យ។
8. សេចក្តីយោងដល់ផ្នែក ប្រការ ភាគី ឧបសម្ព័ន្ធ ឯកសារបង្ហាញ ឬសេចក្តីបន្ថែម គឺជាការសំដៅដល់ផ្នែក ប្រការ ភាគី ឧបសម្ព័ន្ធ ឯកសារបង្ហាញឬសេចក្តីបន្ថែមនៃខចែង និងលក្ខខណ្ឌទាំងនេះ ហើយឯកសារយោងដែលភ្ជាប់ទៅនឹងខចែង និងលក្ខខណ្ឌទាំងនេះ រាប់បញ្ចូលទាំងឧបសម្ព័ន្ធ ឯកសារបង្ហាញ និងសេចក្តីបន្ថែមណាមួយផងដែរ។
9. ចំណងជើង ត្រូវបានប្រើប្រាស់សម្រាប់ងាយស្រួលអាន និងមិនប៉ះពាល់ដល់ការបកស្រាយខចែង និងលក្ខខណ្ឌទាំងនេះឡើយ។
   i. ប្រតិបត្តិការទូទាត់ត្រូវបានធានាលុះត្រាបានគោរពតាមលក្ខខណ្ឌសុវត្ថិភាពទាំងអស់ដែលជាការទទួលខុសត្រូវរបស់អ្នកទទួល និងជាពិសេសត្រូវស្នើសុំការអនុម័តសម្រាប់ចំនួនទឹកប្រាក់លើសពីដែនកំណត់ជាក់លាក់ដែលជា "ចំណុចដែលត្រូវសុំការអនុញ្ញាត" ដែលតាមរយៈនេះចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតនឹងត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។
   ii. រាល់ព័ត៌មានដែលធនាគារបានប្រមូលនឹងត្រូវប្រើប្រាស់នឹងបង្ហាញទៅដល់ភាគីផ្សេងទៀតតាមការចាំបាច់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការដែលបានធ្វើឡើងយោងតាមកិច្ចសន្យានេះ ឬសម្រាប់គោលបំណងនៃការអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិតែប៉ុណ្ណោះ។ ដូចនេះ ធនាគារត្រូវបានអនុញ្ញាតឱ្យរួចផុតពីរាល់កាតព្វកិច្ចការសម្ងាត់របស់ធនាគារ។

# 2. ប្រការ 2 ៖ អំពីប្រព័ន្ធ

ប្រព័ន្ធទូទាត់ដោយប្រើKHQR ពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណិតរបស់ធនាគារ រួមមានការប្រើប្រាស់ KHQR របស់ធនាគារសម្រាប់ការទូទាត់ថ្លៃ ទំនិញដែលបានទិញ ឬជួល ឬសេវាដែលបានផ្តល់ជូនដោយអ្នកទទួលតែម្នាក់ ដោយអនុលោមតាមខចែង និងលក្ខខណ្ឌដែលបានកំណត់ ឬអនុម័តដោយធនាគារ។

# 3. ប្រការ 3 ៖ កាតព្វកិច្ចរបស់អ្នកទទួល

### 3.1 កាតព្វកិច្ចទូទៅ

អ្នកត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវ (រួមមានដូចជា ការបង់ថ្លៃសេវាពាក់ព័ន្ធណាមួយ) ដែលមាននៅក្នុង៖

1. ទម្រង់ពាក្យស្នើសុំរបស់ពាណិជ្ជករ
2. ខចែង និងលក្ខខណ្ឌសម្រាប់ពាណិជ្ជករ
3. សេចក្តីណែនាំលើប្រតិបត្តិការសម្រាប់ពាណិជ្ជករ
4. សៀវភៅណែនាំ ឬការណែនាំ ឬសម្ភារៈផ្សេងទៀតដែលធនាគារផ្តល់ជូនពាណិជ្ជករ (ដោយលាយលក្ខណ៍អក្សរ ឬមិនលាយលក្ខណ៍អក្សរក្តី) សម្រាប់គោលបំណងនៃលក្ខខណ្ឌទាំងនេះ ទោះជាមាន ឬពុំមានចែងច្បាស់លាស់នៅក្នុងខចែង និងលក្ខខណ្ឌទាំងនេះក៏ដោយ។
5. ច្បាប់របស់និយ័តករទៅតាមការការជូនដំណឹងរបស់ធនាគារទៅកាន់ពាណិជ្ជករ។
6. ធនាគារផ្តល់នូវមុខងារទូរគមនាគមន៍ ដើម្បីអាចឱ្យពាណិជ្ជករទទួលបានការជូនដំណឹងអំពីការទូទាត់តាម KHQR តាមរយៈកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម។ ពាណិជ្ជករត្រូវទទួលខុសត្រូវដោយខ្លួនឯងពាក់ព័ន្ធនឹងការប្រើប្រាស់មុខងារនេះ។ ធនាគារនឹងមិនទទួលខុសត្រូវចំពោះការមិនដំណើរការរបស់កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ការគ្រប់គ្រងការជូនដំណឹងជាក្រុម និងការចែករំលែកព័ត៌មានអំពីការទូទាត់ចូល ឬបញ្ហាពាក់ព័ន្ធផ្សេងទៀតឡើយ ប្រសិនបើមាន។

នៅក្នុងករណីមានភាពមិនត្រូវគ្នារវាងឯកសារដែលបានលើកឡើងខាងលើត្រូវអនុវត្តតាមវិធានដូចតទៅ៖ (ក) ទម្រង់ពាក្យសុំរបស់ពាណិជ្ជករមានអាទិភាពជាងឯកសារផ្សេងទៀតទាំងអស់ និង (ខ) ខចែង និងលក្ខខណ្ឌសម្រាប់ពាណិជ្ជករនឹងមានអាទិភាពជាងឯកសារទាំងអស់។

### 3.2 កាតព្វកិច្ចជាក់លាក់ចំពោះធនាគារ

ពាណិជ្ជករត្រូវតែ៖

1. ធ្វើប្រតិបត្តិការតាមរយៈ KHQR ដោយប្រើឧបករណ៍ទូទាត់ ឬឧបករណ៍ផ្សេងទៀត និងបង្ហាញម៉ាកសញ្ញារបស់ប្រព័ន្ធបាគង និងសញ្ញាសម្គាល់ធនាគារដែលធនាគារបានផ្តល់ជូន។
2. អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជាទាំងអស់ដែលមានជាធរមាន
3. ជូនដំណឹងដល់ធនាគារភ្លាមៗប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់ពាណិជ្ជករមានការផ្លាស់ប្តូរដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់ពាណិជ្ជករក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមឯកសារពាណិជ្ជករ ឬវិធានរបស់និយ័តករ
4. ប្រើប្រាស់តែឧបករណ៍ទូទាត់ និងឧបករណ៍ដែលបានទទួលការអនុញ្ញាតពីធនាគារតែប៉ុណ្ណោះ
5. ដាក់ស្នើសុំឱ្យធនាគារដំណើរការ តែកំណត់ត្រាប្រតិបត្តិការណាដែលមានប្រភពចេញពីកន្លែងដែលធនាគារអនុញ្ញាតតែប៉ុណ្ណោះ
6. មិនធ្វើការផ្លាស់ប្តូរធំដុំណាមួយទៅលើទំនិញ និងសេវាកម្មដែលពាណិជ្ជករលក់ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារ (ដែលធនាគារនឹងមិនបដិសេធដោយគ្មានមូលហេតុឡើយ)
7. អនុញ្ញាតឱ្យ បុគ្គលិក អ្នកម៉ៅការ ឬ ភ្នាក់ងាររបស់ធនាគារ ឬប្រតិបត្តិករទាំងឡាយចូលទៅក្នុងបរិវេណរបស់ពាណិជ្ជករនៅពេលដែលមានការស្នើសុំត្រឹមត្រូវ ក្នុងអំឡុងពេលម៉ោងប្រតិបត្តិការអាជីវកម្ម ដើម្បីត្រួតពិនិត្យអនុលោមភាពទៅនឹងឯកសារពាណិជ្ជករ ឬដើម្បីត្រួតពិនិត្យអនុលោមភាពទៅនឹងវិធានរបស់និយ័តករដែលពាក់ព័ន្ធ។
8. អនុញ្ញាតឱ្យបុគ្គលិក អ្នកម៉ៅការ ឬភ្នាក់ងាររបស់ធនាគារចូលទៅក្នុងបរិវេណរបស់ខ្លួននៅពេលមានការស្នើសុំត្រឹមត្រូវក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ដើម្បីដំឡើង ត្រួតពិនិត្យ ថែទាំ និងដកឧបករណ៍ទូទាត់ ឧបការណ៍ពាក់ព័ន្ធនានា
9. ផ្តល់ជូនធនាគារនូវរាល់ព័ត៌មាន និងជំនួយទាំងអស់ដែលធនាគារត្រូវការដោយសមហេតុផល ដើម្បីអនុវត្តកាព្វកិច្ចរបស់ខ្លួនស្ថិតក្រោមឯកសារពាណិជ្ជករ
10. ចុះហត្ថលេខាលើឯកសារដែលធនាគារស្នើសុំដោយត្រឹមត្រូវឱ្យពាណិជ្ជករចុះហត្ថលេខា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងឯកសារពាណិជ្ជករ។
11. ប្រសិនបើការធ្វើឥណពន្ធណាមួយនៅក្រោមប្រការ 13.2 ធ្វើឱ្យគណនីថ្លៃសេវាមិនមានទឹកប្រាក់គ្រប់គ្រាន់ នោះត្រូវដាក់ប្រាក់បន្ថែមភ្លាមៗដើម្បីកាត់កម្រៃសេវាចេញពីថ្លៃសេវា។
12. ដោយសារតែពាណិជ្ជករទទួលបានការផ្តល់ជូននូវម៉ាស៊ីនទូទាត់ពីធនាគារ ពាណិជ្ជករត្រូវ

    i. ដំណើរការប្រតិបត្តិការដោយប្រើប្រាស់ KHQR តែនៅក្នុងលក្ខខណ្ឌដែលរបាយការណ៍ប្រតិបត្តិការដែលជោគជ័យ គឺដូចគ្នាទាំងនៅលើទូរសព្ទរបស់អ្នកប្រើប្រាស់ KHQR និងនៅលើបង្កាន់ដៃប្រតិបត្តិការ KHQR ឬព័ត៌មានលម្អិតនៃការជូនដំណឹង។

13. ត្រូវដាក់បង្ហាញឱ្យច្បាស់នូវរាល់ស្លាកសញ្ញា សម្ភារៈផ្សព្វផ្សាយទីផ្សារដែលធនាគារបានផ្តល់ជូនពាណិជ្ជករទាក់ទងនឹងគោលការណ៍នៃវិធាន និងនីតិវិធីបាគង នៅកន្លែងរបស់ពាណិជ្ជករ និងកន្លែងអាជីវកម្មដែលធនាគារបានអនុញ្ញាត និងមិនត្រូវប្រើស្លាកសញ្ញា ឬសម្ភារៈផ្សព្វផ្សាយទីផ្សារដែលទាក់ទងទៅនឹងគោលការណ៍វិធាន និងនីតិវិធីបាគង ណាផ្សេងឡើយ លុះត្រាតែមានការអនុញ្ញាតពីធនាគារ។

14. អនុញ្ញាតឱ្យធនាគារត្រួតពិនិត្យ និងពិនិត្យមើលសៀវភៅគណនី និងកំណត់ត្រារបស់ពាណិជ្ជករ ដែលទាក់ទងនឹងប្រតិបត្តិការ KHQR ទាំងអស់។

15. ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគារឱ្យបាន 14 ថ្ងៃ យ៉ាងតិច មុនពេលប្តូរឈ្មោះពាណិជ្ជកររបស់ពាណិជ្ជកម្ម។

16. ត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគាឱ្យបាន 7 ថ្ងៃយ៉ាងតិច មុនពេលលក់ ឬផ្ទេរកម្មសិទ្ធិអាជីវកម្មរបស់ពាណិជ្ជករ និងបញ្ចូលទៅក្នុងសេចក្តីជូនដំណឹងនោះនូវអាសយដ្ឋានអាជីវកម្មថ្មី។

17. ប្រើតែម៉ាស៊ីន ឬឧបករណ៍ដែលបង្ហាញកំណត់ត្រាប្រតិបត្តិការដែលបង្ហាញឈ្មោះពាណិជ្ជកម្មរបស់ពាណិជ្ជករ ដូចដែលមានពីពេលមួយទៅពេលមួយ។

18. មិនដាក់ស្នើទៅធនាគារឱ្យដំណើរការបើទោះបីជាដោយផ្ទាល់ ឬដោយប្រយោលនូវរាល់កំណត់ត្រាប្រតិបត្តិការ ដែលមិនមានប្រភពមកពីប្រតិបត្តិការរវាងអ្នកប្រើប្រាស់ KHQR និងពាណិជ្ជករ ឬពាណិជ្ជករដឹង ឬគួរបានដឹងថាជាការក្លែងបន្លំ ឬមិនបានទទួលការអនុញ្ញាតពីអ្នកប្រើប្រាស់ KHQR ។

19. មិនធ្វើការធានា ឬអះអាងណាមួយទាក់ទងនឹងទំនិញ ឬសេវាកម្ម ដែលអាចភ្ជាប់កាតព្វកិច្ចធនាគារ ឬវិធាន និងនីតិវិធីបាគង

20. មិនទទួលយកប្រតិបត្តិការ ដែលជាប្រភេទប្រតិបត្តិការ ដែលធនាគារបានណែនាំពាណិជ្ជករជាមុនថាមិនឱ្យទទួលយក។

21. ផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់និយោជិតរបស់ពាណិជ្ជករ ដើម្បីធានាថាអាចបំពេញកាតព្វកិច្ចពាណិជ្ជករយោងតាមឯកសារពាណិជ្ជករ និងវិធាន និងនីតិវិធីបាគង ណាមួយ។

22. មិនត្រូវចាប់ផ្តើមប្រតិបត្តិការដោយប្រើ KHQR ណាមួយដោយប្រើម៉ាស៊ីនទូទាត់ ឬម៉ាស៊ីនបោះពុម្ពវិក្កយបត្រដោយប្រើគណនីរបស់ពាណិជ្ជករ ឬគណនីរបស់និយោជិតខ្លួនណាមួយឡើយ លុះត្រាតែពាណិជ្ជករ ឬបុគ្គលិករបស់ពាណិជ្ជករទិញទំនិញ ឬសេវាកម្មពីអាជីវកម្មរបស់ពាណិជ្ជករ។

23. មិនធ្វើប្រតិបត្តិការដោយ KHQR ដោយប្រើម៉ាស៊ីនទូទាត់ ឬម៉ាស៊ីនបោះពុម្ពសម្រាប់គោលបំណងផ្សេងទៀតដែលមិនទាក់ទងនឹងអាជីវកម្មរបស់អ្នក លើកលែងតែមានការអនុញ្ញាតពីធនាគារជាលាយលក្ខណ៍អក្សរ។

24. មិនអនុញ្ញាតឱ្យនរណាម្នាក់ក្រៅពីបុគ្គលិកធនាគារដែលមានការអនុញ្ញាត និង/ឬបុគ្គលិកដែលមានការអនុញ្ញាតរបស់អ្នកដំណើរការម៉ាស៊ីនទូទាត់ ឬម៉ាស៊ីនបោះពុម្ពឡើយ។

### 3.3 កាតព្វកិច្ចទាក់ទងនឹងអ្នកប្រើប្រាស់ KHQR

ពាណិជ្ជករត្រូវ

1. បង្ហាញកម្រៃសេវាណាមួយឱ្យបានច្បាស់ មុនពេលដំណើរការប្រតិបត្តិការដោយប្រើ KHQR ហើយការដំណើរការត្រូវធ្វើឡើងតាមរបៀបដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ KHQR អាចលុបចោលប្រតិបត្តិការបានប្រសិនបើពួកគាត់ចង់ដោយឥតគិតកម្រៃសេវា។

2. មិនលក់ ទិញ ផ្តល់ ឬផ្លាស់ប្តូរព័ត៌មាន ឬឯកសារ ឬលេខគណនីណាមួយរបស់អ្នកប្រើប្រាស់ KHQR ទៅកាន់បុគ្គលណាម្នាក់ក្រៅពីធនាគារ និងតាមច្បាប់។



### 3.4 កាតព្វកិច្ចផ្សេងទៀត

បន្ថែមពីលើកាតព្វកិច្ចផ្សេងទៀតរបស់ពាណិជ្ជករយោងតាមឯកសារពាណិជ្ជករ និងវិធានកម្មវិធីណាមួយ ៖

1. អ្នកទទួល

    i. មិនត្រូវបញ្ជូនប្រតិបត្តិការ KHQR ក្លែងបន្លំទៅធនាគារទេ

    ii. ត្រូវបញ្ចូលបង្កាន់ដៃសង្ខេបរបស់ពាណិជ្ជករដែលមានព័ត៌មានលម្អិតរបស់ពាណិជ្ជករបោះពុម្ពនៅលើនោះដោយប្រើម៉ាស៊ីនបោះពុម្ពដែលបានអនុម័តដោយធនាគារតែប៉ុណ្ណោះ

    iii. មិនត្រូវឆូត ឬបញ្ចូលទិន្នន័យកាតដោយប្រើម៉ាស៊ីនទូទាត់ ឬឧបករណ៍ដែលធនាគារមិនអនុញ្ញាតឡើយ

    iv. ត្រូវយោងតាមច្បាប់ ឬវិធានការច្បាប់ទាំងអស់ប្រសិនបើពាណិជ្ជករប្រព្រឹត្តិបទល្មើសលាងសម្អាតប្រាក់

## 4. ប្រការ 4 ៖ ភារកិច្ចរបស់ធនាគារ

ធនាគារត្រូវ

1. ផ្តល់ការបណ្តុះបណ្តាលដល់ពាណិជ្ជករ ត្រូវផ្តល់ព័ត៌មានអំពីការដំណើរការប្រព័ន្ធទូទាត់អេឡិចត្រូនិក និងការអភិវឌ្ឍន៍នានាដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយពាណិជ្ជករ នៅពេលមានការស្នើសុំពីពាណិជ្ជករ ។

2. ផ្តល់ជូនពាណិជ្ជករនូវព័ត៌មានដែលពាក់ព័ន្ធនឹងសុវត្ថិភាពប្រតិបត្តិការ ជាពិសេសការចូលទៅកាន់ប្រព័ន្ធស្នើសុំការអនុញ្ញាតដោយយោងតាមលក្ខខណ្ឌពិសេសដែលបានព្រមព្រៀងជាមួយជាមួយពាណិជ្ជករ។

3. បញ្ចូលបរិមាណលក់សរុបដែលបានរៀបចំដោយអនុលោមតាមលក្ខខណ្ឌនៃឯកសារពាណិជ្ជករទៅក្នុងគណនីទូទាត់ និងបង្ហាញទៅធនាគារ ហើយធនាគាររក្សាសិទ្ធិក្នុងការទូទាត់សងត្រឡប់មកវិញនូវចំនួនទឹកប្រាក់នៃប្រតិបត្តិការលក់ ដោយផ្អែកលើគោលការណ៍កំណត់ដែលថា ការបញ្ចូលទឹកប្រាក់ក្នុងគណនីទូទាត់របស់ធនាគារមានប្រសិទ្ធភាពក្នុងការដំណើរការបំណុលរបសអ្នកទូទាត់ជាមួយពាណិជ្ជករ និងកាតព្វកិច្ចណាមួយដែលធនាគារអាចមានចំពោះពាណិជ្ជករ។

## 5. ប្រការ 5 ៖ ការធានានៃការទូទាត់

1. ប្រតិបត្តិការទូទាត់ត្រូវបានធានាដោយអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពទាំងអស់ដែលជាការទទួលខុសត្រូវរបស់ពាណិជ្ជករដូចដែលបានកំណត់នៅក្នុងខចែង និងលក្ខខណ្ឌទូទៅទាំងនេះ ក៏ដូចជានៅក្នុងខចែង និងលក្ខខណ្ឌប្រតិបត្តិការពិសេស។

2. នីតិវិធីសុវត្ថិភាពទាំងអស់មិនពាក់ព័ន្ធគ្នាឡើយ។ ឧទាហរណ៍ ការយល់ព្រមដែលអនុម័តដោយប្រព័ន្ធផ្តល់សិទ្ធិនឹងមានសុពលភាពជាការធានា តែក្នុងករណីដែលនីតិវិធីសុវត្ថិភាពផ្សេងទៀតត្រូវបានអនុវត្តតែប៉ុណ្ណោះ ជាពិសេសការផ្ទៀងផ្ទាត់លេខកូដសម្ងាត់ ឬលេខសម្ងាត់ (PIN) ។

3. ក្នុងករណីមានការបំពានលើនីតិវិធីណាមួយ វិក្កយបត្រ និងកំណត់ត្រានឹងត្រូវបានទូទាត់ដោយយោងតាមរបាយការណ៍ទូទាត់ចុងក្រោយប៉ុណ្ណោះ។

## 6. ប្រការ 6 ៖ នីតិវិធីសុវត្ថិភាព

1. ពាណិជ្ជករត្រូវរាយការណ៍ភ្លាមៗទៅធនាគារអំពីបញ្ហាដំណើរការខុសប្រក្រតីរបស់ម៉ាស៊ីនទូទាត់ និងភាពមិនប្រក្រតីផ្សេងទៀត (ខ្វះបង្កាន់ដៃ ឬបច្ចុប្បន្នភាពបញ្ជីខ្មៅ អលទ្ធភាពក្នុងការជួសជុលភ្លាមៗ)។

2. ប្រគល់បង្កាន់ដៃច្បាប់ចម្លងពីម៉ាស៊ីនទូទាត់ដែលមានពាក្យថា សម្រាប់អតិថិជន ជូនទៅ អតិថិជន

### 6.1 ប្រតិបត្តិការគ្មានសុពលភាព

ប្រតិបត្តិការដោយប្រើ KHQR នឹងមិនមានសុពលភាពទេ ប្រសិនបើប្រតិបត្តិការ ដែលអ្នកបានធ្វើមិនគោរពតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងឯកសារពាណិជ្ជករ ឬវិធាន និងនីតិវិធីបាគង ។ ដោយមិនដាក់កម្រិតទៅលើខ្លឹមសារក្នុងប្រការ 6.1 នេះ ប្រតិបត្តិការនឹងមិនមានសុពលភាពទេប្រសិនបើ៖

1. ជាប្រតិបត្តិការខុសច្បាប់។
2. ធនាគារបានជំរាបជូនជាមុន នូវការមិនទទួលយកប្រតិបត្តិការ
3. ប្រតិបត្តិការ មិនទទួលបានការអនុញ្ញាតពីម្ចាស់អ្នកប្រើប្រាស់ KHQR។
4. ព័ត៌មានលម្អិតនៅលើច្បាប់ចម្លងនៃកំណត់ត្រាប្រតិបត្តិការដែលបានផ្តល់ឱ្យម្ចាស់/អ្នកប្រើប្រាស់ KHQR មិនដូចគ្នានឹងព័ត៌មានលម្អិតនៅលើកំណត់ត្រាប្រតិបត្តិការណាមួយ
5. សេវាកម្មរបស់ពាណិជ្ជករត្រូវបានបញ្ឈប់មុនកាលបរិច្ឆេទនៃប្រតិបត្តិការ។
6. សក្ខីបត្រលក់សម្រាប់ប្រតិបត្តិការដែលបានធ្វើមិនបានបង្ហាញនូវចំណុចដូចខាងក្រោម៖
    i. ព័ត៌មានលម្អិតរបស់ពាណិជ្ជករដូចដែលពាណិជ្ជករបានជូនដំណឹងដល់ធនាគារចុងក្រោយបំផុត
    ii. កាលបរិច្ឆេទប្រតិបត្តិការ
    iii. ចំនួនទឹកប្រាក់នៃការលក់
    iv. ព័ត៌មានលម្អិតនៃការទិញ
    v. លេខនៃលិខិតអនុញ្ញាត ប្រសិនបើចាំបាច់
7. កំណត់ត្រាប្រតិបត្តិការមិនពេញលេញ ឬមិនអាចយល់បាន

### 6.2 ប្រតិបត្តិការដែលមិនអាចទទួលយកបាន

តាមការសម្រេចចិត្តរបស់ធនាគារ ប្រតិបត្តិការនឹងមិនអាចទទួលយកបានទេប្រសិនបើ៖

1. ការបដិសេធទទួលខុសត្រូវលើប្រតិបត្តិការដោយសារមូលហេតុណាមួយ ឬការទាមទារធ្វើការកាត់កង ឬតវ៉ាចំពោះប្រតិបត្តិការ ឬ
2. ប្រតិបត្តិការស្ថិតនៅក្នុងចំណាត់ថ្នាក់ដែលធនាគារសម្រេចចិត្ត តាមឆន្ទានុសិទ្ធិរបស់ខ្លួនថាមិនអាចទទួលយកបាន។

### 6.3 ការដោះស្រាយវិវាទ

ពាណិជ្ជករត្រូវដាក់ចំនួនប្រាក់ដែលកាត់សង បញ្ចូលទៅក្នុងគណនីរបស់ពាណិជ្ជករ ប្រសិនបើគណនីមានទឹកប្រាក់មិនគ្រប់គ្រាន់។ ក្នុងករណីដែលពាណិជ្ជករមានទឹកប្រាក់ក្នុងគណនីនោះគ្រប់គ្រាន់ ធនាគារមានសិទ្ធិពេញលេញក្នុងការដក (បង្ខំដក) នូវចំនួនទឹកប្រាក់ពីគណនីរបស់ពាណិជ្ជករ។ ក្នុងករណីដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះធនាគាររក្សាសិទ្ធិក្នុងការចាត់វិធានការតាមផ្លូវច្បាប់តាមការចាំបាច់។



## 7. ប្រការ 7 ៖ លក្ខខណ្ឌប្រតិបត្តិការដែលពាក់ព័ន្ធ

### 7.1 បណ្តឹងតវ៉ា និងការទាមទារ

រាល់ការប្តឹងតវ៉ា ឬការទាមទារត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់ធនាគារក្នុងរយៈពេលយ៉ាងយូរ 6 ខែ គិតចាប់ពីថ្ងៃប្រតិបត្តិការដែលមានការប្តឹងតវ៉ា។ រយៈពេលនេះត្រូវបានបន្ថយមកត្រឹម 15 ថ្ងៃដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃការផ្ញើប្រាក់ដែលនៅសេសសល់ ប្រសិនបើការប្តឹងតវ៉ាទាក់ទងនឹងទឹកប្រាក់មិនទាន់ទូទាត់។

## 8. ប្រការ 8 ៖ ការកែប្រែខចែង និងលក្ខខណ្ឌនៃកិច្ចសន្យា

1. ធនាគារអាចនឹងកែប្រែខចែង និងលក្ខខណ្ឌទូទៅនៃសមាជិកភាពទាំងនេះ និងលក្ខខណ្ឌពិសេសនៅពេលណាមួយដោយផ្អែកលើមូលដ្ឋានបច្ចេកទេស ហិរញ្ញវត្ថុ ឬសុវត្ថិភាពនៃការទូទាត់ប្រាក់។
2. ការកែប្រែលក្ខណៈបច្ចេកទេស ក្រៅពីការងារដំឡើង និងថែទាំ ពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មវិធី software ការផ្លាស់ប្តូរប៉ារ៉ាម៉ែត្រមួយចំនួន ការដាក់ឱ្យដំណើរការឡើងវិញនូវប្រព័ន្ធទូទាត់ប្រាក់ បន្ទាប់ពីមានបញ្ហាខុសប្រក្រតីមួយចំនួន។ល។
3. ការផ្លាស់ប្តូរទាក់ទងនឹងសុវត្ថិភាពទាក់ទងនឹងជាពិសេសទៅនឹង
    i. ការផ្លាស់ប្តូរកម្រិតទឹកប្រាក់អប្បបរមាដែលអនុញ្ញាតមុនពេលទទួលបានការអនុញ្ញាត
    ii. ការព្យួរសមាជិកភាពនៃសេវាទូទាត់
4. ខចែង និងលក្ខខណ្ឌថ្មីណាមួយដែលចូលជាធរមាននៅថ្ងៃដែលពាណិជ្ជករទទួលបានការជូនដំណឹងអំពីការកែប្រែ ឬកាលបរិច្ឆេទក្រោយមកទៀតដែលធនាគារបានបញ្ជាក់។
5. ការមិនអនុលោមតាមលក្ខខណ្ឌបច្ចេកទេស ឬសុវត្ថិភាពថ្មីក្នុងរយៈពេលដែលបានផ្តល់អាចបណ្តាលឱ្យមានការសម្រេចចិត្តចុងក្រោយលើកិច្ចសន្យា ឬរហូតដល់ការផ្អាកសមាជិកភាពនៃប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងករណីមានហានិភ័យធំ។

## 9. ប្រការ 9 ៖ ការបញ្ចប់ខចែង និងលក្ខខណ្ឌហ្វាស៊ីលីធីពាណិជ្ជករ

1. ខចែង និងលក្ខខណ្ឌពាណិជ្ជករ នឹងត្រូវចូលមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ (ថ្ងៃ/ខែ/ឆ្នាំ) ហើយត្រូវមានសុពលភាពរហូតដល់កាលបរិច្ឆេទបញ្ចប់ដោយអ្នកទទួល ឬធនាគារ។
2. ខចែង និងលក្ខខណ្ឌពាណិជ្ជករ អាចនឹងត្រូវបញ្ចប់តាមលក្ខខណ្ឌដូចខាងក្រោម៖
    i. ទិន្នន័យគណនីខូច
    ii. ការបំពានស្តង់ដារ
    iii. ការឃុបឃិតរបស់ម្ចាស់ពាណិជ្ជករ
    iv. ប្រតិបត្តិការខុសច្បាប់
    v. រកឃើញការលួច
    vi. ការសម្អាតប្រាក់
    vii. ការចោទប្រកាន់ពីបទកេងបន្លំ
    viii. ក្ស័យធន/ការជម្រះបញ្ជី/អសាធនភាព
    ix. រាល់ករណី ឬកាលៈទេសៈដែលជាគំនិតរបស់ធនាគារ

3. ខចែង និងលក្ខខណ្ឌពាណិជ្ជករអាចនឹងត្រូវបញ្ចប់៖

    i. នឹងមានប្រសិទ្ធិភាពភ្លាមៗដោយធនាគារ នៅពេលណាមួយដោយមិនចាំបាច់មានមូលហេតុ ឬការជូនដំណឹងជាមុននោះទេ (លើកលែងតែមានការឯកភាពគ្នាជាពិសេសរវាងគូភាគី) អាស្រ័យតាមការដំណើរការប្រតិបត្តិការដែលនៅសេសសល់តាមរយៈលិខិតទទួលស្គាល់ការទទួលបានដែលចុះលេខដោយមិនចាំបាច់មានបែបបទផ្លូវការបន្ថែមឡើយ។

    ii. ពាណិជ្ជករត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ធនាគារក្នុងរយៈពេលសាបសិប (30) ថ្ងៃ មុនពេលបញ្ចប់ខចែង និងលក្ខខណ្ឌហ្វាស៊ីលីធីដែលបានលើកឡើងខាងលើ។

    iii. ភ្លាមៗបន្ទាប់ពីបញ្ចប់សកម្មភាពរបស់អ្នកទទួល ការលក់ ឬការផ្ទេរអាជីវកម្ម អាស្រ័យលើការបញ្ចប់ប្រតិបត្តិការដែលនៅសេសសល់។

4. នៅពេលទទួលស្គាល់ការទទួលបានសេចក្តីជូនដំណឹងអំពីការបញ្ចប់ លក្ខខណ្ឌខាងក្រោមនឹងមានប្រសិទ្ធភាពអនុវត្ត៖

    i. គណនីរបស់ពាណិជ្ជករត្រូវតែបិទនៅក្នុងរយៈពេលសាមសិប (30) ថ្ងៃប្រតិទិន

    ii. ការផុតកំណត់ ឬការបញ្ចប់សេវាអាជីវកម្មមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកទទួល ឬសិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារដែលកើតឡើងមុនពេលបញ្ចប់សេវានោះទេ ដែលក្នុងនោះរួមមានជាអាទិ៍ និងពាក់ព័ន្ធនឹងសិទ្ធិរបស់ធនាគារនៅក្នុងការដោះស្រាយវិវាទ និងសិទ្ធិរបស់ធនាគារក្នុងការទាមទារថ្លៃចំណាយ និងកម្រៃសេវាផ្សេងៗដែលកើតឡើង។

    iii. ប្រសិនបើរកឃើញថាមានការទូទាត់នៅសេសសល់ក្រោយពេលបញ្ចប់ខចែង និងលក្ខខណ្ឌពាណិជ្ជករ ការទូទាត់សេសសល់នោះ គឺជាបន្ទុករបស់ពាណិជ្ជករ ឬអាចនឹងអាស្រ័យទៅលើសេចក្តីថ្លែងទាមទារ។

    iv. ពាណិជ្ជករនឹងត្រូវប្រគល់ជូនធនាគារវិញនូវឧបករណ៍របស់ធនាគារដែលខ្លួនប្រើប្រាស់ដូចជាឧបករណ៍អេឡិចត្រូនិក បរិក្ខារសន្តិសុខ និងឯកសារទាំងអស់។ លើកលែងតែពាណិជ្ជករបានចុះកិច្ចព្រមព្រៀងសមាជិកភាពមួយ ឬច្រើន បើមិនដូច្នោះទេ ពាណិជ្ជករត្រូវដកស្លាកសញ្ញានៃការទទួលយកការទូទាត់ទាំងអស់ភ្លាមៗចេញពីបរិវេណរបស់ខ្លួន។

# 10. ប្រការ 10 ៖ ការផ្អាកដំណើការ ឬការលុបចោលសមាជិកភាព

1. ធនាគារអាចនឹងផ្អាកដំណើរការសមាជិកភាពសម្រាប់ប្រព័ន្ធទូទាត់អេឡិចត្រូនិកដោយសារមូលហេតុសន្តិសុខ ដោយពុំចាំបាច់ជូនដំណឹងជាមុន ហើយអាស្រ័យលើការបញ្ចប់ប្រតិបត្តិការដែលមិនទាន់សម្រេច។ ការផ្អាកដំណើរការនេះអាចនឹងចាប់ផ្តើមដំបូងដោយការព្រមានដល់ពាណិជ្ជករ ឬកាត់បន្ថយសិទ្ធិមកត្រឹមកម្រិតជាក់លាក់ណាមួយទៅតាមករណីជាក់ស្តែង។ ការផ្អាកនេះនឹងត្រូវជូនដំណឹងតាមរយៈលិខិតដែលបានចុះលេខ ដោយមានបញ្ជាក់អំពីមូលហេតុ និងបញ្ជាក់ការទទួលបានលិខិតនោះ។ ការផ្អាកនេះនឹងមានសុពលភាពភ្លាមៗ។ ការផ្អាកនេះអាចនឹងត្រូវសម្រេចជាពិសេស ដោយសារមូលហេតុដូចខាងក្រោម៖

    i. ការប្រើប្រាស់ម៉ាស៊ីនទូទាត់ ឬឧបករណ៍ដោយមិនមានការអនុញ្ញាត

    ii. ហានិភ័យការមិនដំណើរការធ្ងន់ធ្ងរនៃប្រព័ន្ធទូទាត់អេឡិចត្រូនិក

    iii. ការសម្អាតប្រាក់ ឬឃុបឃិតគ្នាធ្វើសកម្មភាពក្លែងបន្លំ

2. ពាណិជ្ជករ សន្យាប្រគល់ជូនធនាគារវិញនូវឧបករណ៍អេឡិចត្រូនិក បរិក្ខារសន្តិសុខ និងឯកសារទាំងអស់ដែលជារបស់ធនាគារ ហើយត្រូវដកស្លាកសញ្ញាទទួលយកការទូទាត់ទាំងអស់ភ្លាមៗចេញពីទីតាំងរបស់ខ្លួនភ្លាមៗ។

3. ក្នុងករណីដែលមានឥរិយាបថក្លែងបន្លំលើផ្នែកណាមួយនៃទំនួលខុសត្រូវរបស់ពាណិជ្ជករនោះពាណិជ្ជករអាចនឹងត្រូវធ្វើការលុបចេញ ឬផ្អាកភ្លាមៗដើម្បីដកហូតម៉ាស៊ីនចេញ។

# 11. ប្រការ 11 ៖ ការមិនលះបង់សិទ្ធិ

ក្នុងករណីដែលពាណិជ្ជករ ឬធនាគារ ខកខានមិនបានគោរពតាមការអនុវត្តខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិនៃកិច្ចសន្យានេះនៅពេលណាមួយ ករណីនោះមិនត្រូវបានចាត់ទុកថាជាការលះបង់សិទ្ធិក្នុងការអនុវត្តបញ្ញត្តិផ្សេងៗទៀតឡើយ។



# 12. ប្រការ 12 ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងការប្រើប្រាស់ម៉ាស៊ីនទូទាត់

## 12.1 ការដំឡើងម៉ាស៊ីនទូទាត់

ប្រសិនបើធនាគារផ្តល់ជូនពាណិជ្ជករនូវម៉ាស៊ីនទូទាត់ ឬឧបករណ៍ នោះពាណិជ្ជករ ត្រូវតែរៀបចំដោយធ្វើការចំណាយផ្ទាល់ខ្លួន នូវទីតាំងក្នុងបរិវេណប្រកបអាជីវកម្មរបស់ខ្លួនឱ្យត្រូវតាមលក្ខណៈបច្ចេកទេសសម្រាប់ការដំឡើងម៉ាស៊ីនទូទាត់ និងឧបករណ៍ រួមទាំងថាមពលអគ្គិសនី និងខ្សែទូរសព្ទដាច់ដោយឡែកពីខ្សែទូរសព្ទជាសំឡេងចម្បងរបស់ពាណិជ្ជករ។

យើងត្រូវទទួលខុសត្រូវចំពោះការដំឡើង ប្រតិបត្តិការ ថែទាំ ការបណ្តុះបណ្តាល និងការធ្វើបច្ចុប្បន្នភាពរបស់ម៉ាស៊ីនទូទាត់។

## 12.2 កម្មសិទ្ធិម៉ាស៊ីនទូទាត់

ប្រសិនបើធនាគារផ្តល់ម៉ាស៊ីនទូទាត់ ឬឧបករណ៍ណាមួយជូនពាណិជ្ជករ ឧបករណ៍នោះនឹងនៅតែជាកម្មសិទ្ធិរបស់ធនាគារដដែល។

## 12.3 ការធានារ៉ាប់រង

ច្បាប់នៃប័ណ្ណធានារ៉ាប់រងលើទំហំរបស់ពាណិជ្ជករ ក៏ត្រូវរ៉ាប់រងទៅលើម៉ាស៊ីនទូទាត់ និងឧបករណ៍ដែលធនាគារបានផ្តល់ជូនពាណិជ្ជករក្នុងតម្លៃធានាអតិបរមា ព្រមទាំងត្រូវមានកំណត់សម្គាល់ពីអត្ថប្រយោជន៍របស់ធនាគារនៅលើប័ណ្ណធានារ៉ាប់រងនោះផងដែរ។

ច្បាប់នៃប័ណ្ណធានារ៉ាប់រងលើទំហំរបស់ពាណិជ្ជករ ក៏ត្រូវរ៉ាប់រងទៅលើម៉ាស៊ីនទូទាត់ និងឧបករណ៍ដែលធនាគារបានផ្តល់ជូនពាណិជ្ជករក្នុងតម្លៃធានាអតិបរមា ព្រមទាំងត្រូវមានកំណត់សម្គាល់ពីអត្ថប្រយោជន៍របស់ធនាគារនៅលើប័ណ្ណធានារ៉ាប់រងនោះផងដែរ។

ពាណិជ្ជករត្រូវតែធានាថាប័ណ្ណធានារ៉ាប់រងរបស់ខ្លួនមានការធានាទៅលើ៖

1. រាល់ហានិភ័យទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងម៉ាស៊ីនទូទាត់ដែលធនាគារមិនអាចទទួលខុសត្រូវបាន ក៏ដូចជាការខូចខាត មិនថាដោយផ្ទាល់ ឬដោយប្រយោលដែលកើតចេញពីការធ្វើឱ្យខូច ឬការថយគុណភាព។

2. ការខូចខាតដោយផ្ទាល់ ឬដោយប្រយោលនិងចំពោះឧបករណ៍បន្ទាប់បន្សំដែលអាចនឹងស្ថិតក្រោមការថែទាំរបស់ខ្លួន។

## 12.4 ការប្រើប្រាស់ និងការថែទាំម៉ាស៊ីនទូទាត់ និងឧបករណ៍ដែលធនាគារបានផ្តល់ជូន

ប្រសិនបើធនាគារផ្តល់ជូនពាណិជ្ជករនូវម៉ាស៊ីនទូទាត់ និង/ឬឧបករណ៍ណាមួយ ពាណិជ្ជករត្រូវ៖

1. យកចិត្តទុកដាក់ថែទាំម៉ាស៊ីនទូទាត់ និងឧបករណ៍ (និងត្រូវអនុវត្តតាមការណែនាំរបស់ធនាគារសម្រាប់ការថែទាំ និងការការពារ ដូចមានចែងនៅក្នុងសេចក្តីណែនាំប្រតិបត្តិសម្រាប់ពាណិជ្ជករ ឬការជូនដំណឹងផ្សេងពីនេះទៅកាន់ពាណិជ្ជករ)។

2. មិនអនុញ្ញាតឱ្យបុគ្គលដែលមិនទទួលបានការបណ្តុះបណ្តាល ឬមិនមានសិទ្ធិ ធ្វើប្រតិបត្តិការ ឬប្រើប្រាស់ម៉ាស៊ីនទូទាត់ និងឧបករណ៍នេះឡើយ។

3. ចេញថ្លៃជួសជុល ឬប្តូរម៉ាស៊ីនទូទាត់ និងឧបករណ៍របស់ធនាគារទៅតាមភាពចាំបាច់ ដោយសារតែពាណិជ្ជករធ្វេសប្រហែស ប្រើប្រាស់មិនត្រឹមត្រូវ និងធ្វើឱ្យខូចខាតម៉ាស៊ីនទូទាត់ និងឧបករណ៍ធនាគារនានា។

4. មិនត្រូវយកម៉ាស៊ីនទូទាត់ និងឧបករណ៍ធនាគារទៅកាន់ទីតាំងណាមួយក្រៅពីបរិវេណដែលបានអនុញ្ញាតដោយធនាគារ ឬធ្វើការបន្ថែម ឬកែប្រែ ឬជួសជុលម៉ាស៊ីនទូទាត់ និងឧបករណ៍ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារឡើយ។ ប្រសិនបើធនាគារអនុញ្ញាតឱ្យមានការយកចេញ កែប្រែ ឬបន្ថែម ឬជួសជុលម៉ាស៊ីនទូទាត់ និងឧបករណ៍នោះពាណិជ្ជករត្រូវឯកភាពថា កិច្ចការនេះនឹងត្រូវអនុវត្តដោយប្រើប្រាស់ការចំណាយផ្ទាល់ខ្លួន ហើយអាចត្រូវអនុវត្តតាមលក្ខខណ្ឌមួយចំនួន។

5. ផ្តល់ជូនធនាគារ និងទីភ្នាក់ងារ ឬក្រុមហ៊ុនម៉ៅការ នូវសិទ្ធិចូលទៅកាន់បរិវេណរបស់ពាណិជ្ជករ ដើម្បីដំឡើង ត្រួតពិនិត្យ

ជួសជុល ថែទាំ ឬដកម៉ាស៊ីនទូទាត់ និងឧបករណ៍។

6. ត្រូវទទួលខុសត្រូវ និងផ្តល់សំណងជូនធនាគារពាក់ព័ន្ធនឹងការខាតបង់ ឬការមិនដំណើរការ ឬការខូចខាតចំពោះម៉ាស៊ីនទូទាត់ និងឧបករណ៍ (ក្រៅពីការខាតបង់ ឬការខូចខាតផ្សេងៗដែលកើតចេញពីបញ្ហាវិការៈក្នុងម៉ាស៊ីនទូទាត់ និងឧបករណ៍ ឬតាមរយៈភាពសឹករេចរិលធម្មតា) និង

7. ប្រើប្រាស់ម៉ាស៊ីនទូទាត់ និងឧបករណ៍ស្របតាមលក្ខណៈដូចមានចែងនៅក្នុងសេចក្តីណែនាំប្រតិបត្តិការរបស់ពាណិជ្ជករ។

### 12.5 ការផ្លាស់ប្តូរម៉ាស៊ីនទូទាត់ និងឧបករណ៍ធនាគារ

ធនាគារអាចនឹង (ដោយបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ពាណិជ្ជករមិនតិចជាង 20 ថ្ងៃ) ដកចេញ និងផ្លាស់ប្តូរ (ដោយប្រើប្រាស់ការចំណាយរបស់ធនាគារ) នូវម៉ាស៊ីនទូទាត់ និងឧបករណ៍ ដែលធនាគារបានផ្តល់ជូនពាណិជ្ជករ។

### 12.6 ការប្រគល់ត្រឡប់មកវិញនូវម៉ាស៊ីនទូទាត់ ឬឧបករណ៍

នៅពេលដែលសេវាពាណិជ្ជករនោះត្រូវបានបញ្ចប់ ម៉ាស៊ីនទូទាត់ ឬឧបករណ៍ដែលធនាគារបានប្រគល់ជូនពាណិជ្ជករចាំបាច់ត្រូវតែប្រគល់ត្រឡប់មកឱ្យធនាគារវិញ ឬអនុវត្តទៅតាមការណែនាំរបស់ធនាគារក្នុងស្ថានភាពល្អ ដូចនៅពេលដែលធនាគារបានប្រគល់ជូនពាណិជ្ជករដែរ។

### 12.7 ការខូចខាត មិនដំណើរការ

ពាណិជ្ជករត្រូវតែប្រាប់ដល់ធនាគារភ្លាមៗនៅពេលដែលខ្លួនបានដឹងអំពីករណីបាត់ មិនដំណើរការ ឬការខូចម៉ាស៊ីនទូទាត់ ឬឧបករណ៍។ ប្រសិនបើម៉ាស៊ីនទូទាត់ ឬឧបករណ៍មិនដំណើរការ ធនាគារត្រូវផ្លាស់ប្តូរម៉ាស៊ីនទូទាត់ ឬឧបករណ៍ពាក់ព័ន្ធថ្មីផ្តល់ជូនពាណិជ្ជករឱ្យបានឆាប់តាមដែលអាចធ្វើទៅបានទៅតាមអត្ថិភាពរបស់ធនាគារ។

## 13. ប្រការ 13 ៖ គណនីថ្លៃសេវា និងគណនីទូទាត់

### 13.1 គណនីថ្លៃសេវារបស់ពាណិជ្ជករ

ពាណិជ្ជករត្រូវតែមានគណនីថ្លៃសេវា។ ពាណិជ្ជករត្រូវធានាថាការបញ្ចប់កាតព្វកិច្ចដែលកើតចេញពីឯកសារពាណិជ្ជករបានធ្វើឡើងតាមរយៈគណនីថ្លៃសេវា។ ពាណិជ្ជករយល់ស្របថាក្នុងវិសាលភាពដែលតម្រូវដោយប្រការ 14 នេះ លក្ខខណ្ឌនៃប្រការនេះ អាចនឹងមានភាពប្រែប្រួល ហើយបង្កើតជាផ្នែកមួយនៃខចែង និងលក្ខខណ្ឌនៃគណនីថ្លៃសេវារបស់ពាណិជ្ជករ។

### 13.2 សិទ្ធិអំណាចក្នុងការប្រើប្រាស់គណនីថ្លៃសេវារបស់ពាណិជ្ជករ

ពាណិជ្ជករអនុញ្ញាតឱ្យធនាគារដកប្រាក់ក្នុងគណនីថ្លៃសេវាជាមួយនឹង៖

1. ថ្លៃសេវាពាណិជ្ជករតាមប្រតិបត្តិការនីមួយៗដែលមានបញ្ជាក់ក្នុងទម្រង់ពាក្យសុំពាណិជ្ជករ។

2. កម្រៃសេវាដែលធនាគារបានជូនដំណឹងដល់អាជីករពីពេលមួយទៅពេលមួយ។

3. ការបញ្ចូលប្រាក់លើសដែលធនាគារបានធ្វើឡើងពាក់ព័ន្ធនឹងប្រតិបត្តិការដោយប្រើកាតដោយសារតែកំហុស ឬកម្រៃជើងសារ។

4. អាករ ពន្ធ ថ្លៃតែម កម្រៃជើងសារ ថ្លៃសេវា ការប្តូរប្រាក់ ការប្តូរប្រាក់ត្រលប់វិញ និងការចំណាយដែលកើតមានដោយលក្ខណៈនៃសកម្មភាពអាជីវកម្ម។

5. ចំនួនទឹកប្រាក់ដែលពាណិជ្ជករទូទាត់ជូនធនាគារខ្វះយោងតាមឯកសារពាណិជ្ជករ ដែលបានបង្ហាញនៅក្នុងការធ្វើសវនកម្ម ឬការត្រួតពិនិត្យ ឬដំណើរការផ្សេងពីនេះ។

6. ច្បាប់ ថ្លៃចំណាយ ឬការចំណាយដែលកើតឡើងដោយធនាគារ មិនថាដោយផ្ទាល់ ឬដោយប្រយោលពាក់ព័ន្ធនឹងឯកសាររបស់ពាណិជ្ជករ។



7. រាល់ការពិន័យ ការផាក ឬការចំណាយស្រដៀងនេះ (មិនថាបកស្រាយដោយរបៀបណា) ដែលបានកំណត់មកលើធនាគារដោយប្រតិបត្តិករដោយសារតែពាណិជ្ជករមិនបានអនុលោមតាម និង

8. រាល់ចំនួនទឹកប្រាក់ដែលពាណិជ្ជករជំពាក់ធនាគារ ស្របតាមឯកសាររបស់ពាណិជ្ជករ។

### 13.3 សិទ្ធិអំណាចក្នុងការប្រើប្រាស់គណនីទូទាត់របស់ពាណិជ្ជករ

ពាណិជ្ជករអនុញ្ញាតឱ្យធនាគារដកប្រាក់ពីគណនីទូទាត់ក្នុងចំនួនពេញតាមសម្ងីប័ត្រឥណទានដែលបានបង្ហាញទៅកាន់ធនាគារដើម្បីដំណើរការ ឬប្រតិបត្តិការផ្ទេរប្រាក់សងតាមប្រព័ន្ធអេឡិចត្រូនិកដែលដំណើរការដោយពាណិជ្ជករស្របតាមខចែង និងលក្ខខណ្ឌ។

### 13.4 សិទ្ធិកាត់ទុក

ធនាគារមានសិទ្ធិកាត់ទុក ឬផ្អាកការទូទាត់ក្នុងចំនួនទឹកប្រាក់ដែលបាននឹងត្រូវជំពាក់ពាណិជ្ជករ រហូតដល់ពេលដែលធនាគារបានបញ្ចប់ការស៊ើបអង្កេត។

### 13.5 សិទ្ធិដកប្រាក់ចេញពីគណនីរបស់ពាណិជ្ជករ

ប្រសិនបើធនាគារបានធ្វើការទូទាត់ប្រាក់ទៅឱ្យពាណិជ្ជករ ហើយការទូទាត់នោះទាំងមូល ឬដោយផ្នែកត្រូវផ្ទេរត្រលប់ ឬប្រសិនបើមានការសង្ស័យណាមួយអំពីសុពលភាព ឬភាពអាចទទួលយកបាននៃប្រតិបត្តិការណាមួយដែលត្រូវបានរាប់បញ្ចូលក្នុងការទូទាត់នោះ ពាណិជ្ជករអនុញ្ញាតឱ្យធនាគារដកប្រាក់ខាងលើចេញពីគណនីថ្លៃសេវា ហើយដាក់ប្រាក់នោះទៅក្នុងគណនីបណ្តោះអាសន្ន (Suspense Account) រហូតទាល់តែយើងខ្ញុំធ្វើការកំណត់ ស្របតាមឆន្ទានុសិទ្ធិរបស់ធនាគារថាការពិនិត្យមើលការស៊ើបអង្កេត ឬវិវាទពាក់ព័ន្ធត្រូវបានដោះស្រាយ។

## 14. ប្រការ 14 ៖ ការធានា

តាមរយៈការផ្តល់ជូនធនាគារនូវកំណត់ត្រាប្រតិបត្តិការ ពាណិជ្ជករធានាចំពោះធនាគារថា៖

- ចំណុចលម្អិតទាំងអស់ដែលបានរៀបចំផ្តល់ជូនធនាគារ គឺពិតប្រាកដ
- ប្រតិបត្តិការគឺជាប្រតិបត្តិការដែលមានសុពលភាព និងជាប្រតិបត្តិការដែលអាចទទួលយកបាន និង
- ព័ត៌មានលម្អិតនៅក្នុងកំណត់ត្រាប្រតិបត្តិការ គឺពិតជាត្រឹមត្រូវ។

## 15. ប្រការ 15 ៖ ការធានាការពាររបស់ពាណិជ្ជករ

អ្នកទទួល នឹងធានាការពារធនាគារ បុគ្គលិក និយោជិត ភ្នាក់ងារ និងក្រុមហ៊ុនម៉ៅការរបស់ធនាគារពីការខាតបង់ ការចំណាយ និងការខូចខាតដែលធនាគារ បុគ្គលិក និយោជិត ភ្នាក់ងារ និងក្រុមហ៊ុនម៉ៅការរបស់ធនាគារអាចនឹងទទួលរងប៉ះពាល់ ឬកើតឡើងដោយសារតែ៖

1. ពាណិជ្ជករខកខានមិនបានគោរពតាមបញ្ញត្តិនៃឯកសារពាណិជ្ជករ

2. ការធានាដែលពាណិជ្ជករបានធ្វើឡើងក្រោមឯកសារពាណិជ្ជករនោះគឺមិនត្រឹមត្រូវ

3. ការបំពានដោយពាណិជ្ជករ ភ្នាក់ងារ ឬនិយោជិតរបស់ពាណិជ្ជករទៅលើកម្មសិទ្ធិបញ្ញារបស់អ្នកផ្សេង

4. រាល់វិវាទដែលកើតឡើងនៅក្នុងពេលណាមួយរវាងពាណិជ្ជករ និងអ្នកទូទាត់ដែលវិវាទនោះកើតឡើងពាក់ព័ន្ធនឹងប្រតិបត្តិការ ឬបញ្ហាឧប្បត្តិហេតុ ឬបញ្ហាបន្ទាប់បន្សំផ្សេងៗ ឬ

5. ការទាមទារមិនថាក្នុងលក្ខណៈណាក៏ដោយ ដែលកើតចេញពីការចូលប្រើប្រាស់ព័ត៌មានប្រតិបត្តិការដោយមិនមានការអនុញ្ញាត ឬការធ្វេសប្រហែស ឬការប្រើប្រាស់បែបក្លែងបន្លំ ឬការប្រើប្រាស់ម៉ាស៊ីនទូទាត់ ឬឧបករណ៍ដោយមិនត្រឹមត្រូវរបស់ពាណិជ្ជករ ភ្នាក់ងារ ឬនិយោជិតរបស់ខ្លួន។

ការធានាការពារនេះត្រូវបន្តមានសុពលភាពទោះបីជាសេវាអាជីករនេះបញ្ចប់ហើយក្តី។

# 16. ប្រការ 16 ៖ ការបដិសេធ

ដរាបណាច្បាប់អនុញ្ញាត ការទទួលខុសត្រូវចំពោះការខាតបង់ ឬការខូចខាតរបស់ធនាគារ ដែលបង្កឡើងដោយការបំពានខចែង លក្ខខណ្ឌ ឬការធានាដែលមានកំណត់ដោយច្បាប់ គឺនឹងត្រូវបានលើកលែង។

# 17. ប្រការ 17 ៖ ព័ត៌មានសម្ងាត់

## 17.1 កាតព្វកិច្ចរក្សាការសម្ងាត់ទូទៅ

អ្នក៖

1. ត្រូវរក្សាទុកព័ត៌មានសម្ងាត់ទាំងអស់ជាការសម្ងាត់ និង

2. អាចប្រើប្រាស់ព័ត៌មានសម្ងាត់បានតែក្នុងករណីពាក់ព័ន្ធនឹងគោលបំណងដែលមានចែងក្នុងខចែង និងលក្ខខណ្ឌនេះប៉ុណ្ណោះ និង

3. អាចបញ្ចេញព័ត៌មានសម្ងាត់នេះបាន ដើម្បីឱ្យពាណិជ្ជករអនុវត្តកាតព្វកិច្ចក្រោមខចែង និងលក្ខខណ្ឌនេះ ប៉ុន្តែបញ្ចេញព័ត៌មានបានតែចំពោះបុគ្គលដែលមានសិទ្ធិត្រូវដឹងប៉ុណ្ណោះ និង

4. មិនត្រូវថតចម្លងព័ត៌មានសម្ងាត់ ឬផ្នែកណាមួយនៃព័ត៌មានសម្ងាត់នេះក្នុងគោលបំណងណាមួយផ្សេង ក្រៅពីគោលបំណងចាំបាច់ដែលកំណត់ក្នុងខចែង និងលក្ខខណ្ឌនេះនោះទេ ហើយត្រូវសរសេរកំណត់សម្គាល់ ប្រសិនបើតម្រូវដោយធនាគារលើឯកសារចម្លងនោះថា “សម្ងាត់ - BRED Bank (Cambodia) Plc.” និង

5. ត្រូវចាត់វិធានការសុវត្ថិភាពលើការចម្លង ការប្រើប្រាស់ ការបញ្ចេញព័ត៌មានដោយមិនមានការអនុញ្ញាត (មិនថាបញ្ចេញព័ត៌មានដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ផ្សេងៗ) ការចូលប្រើប្រាស់ និងការបំផ្លាញ ឬការធ្វើឱ្យខូច និង

6. ត្រូវជូនដំណឹងដល់ធនាគារ ប្រសិនបើអ្នកមានការសង្ស័យ ឬដឹងអំពីការចម្លង ការប្រើប្រាស់ ការបញ្ចេញព័ត៌មាន ការចូលប្រើប្រាស់ ការបំផ្លាញ ឬការធ្វើឱ្យខូចខាតទិន្នន័យក្នុងទម្រង់ណាមួយ និងនៅក្នុងវិសាលភាពណាមួយ។

7. ត្រូវអនុលោមតាមការណែនាំសមហេតុផលរបស់ធនាគារពាក់ព័ន្ធនឹងព័ត៌មានសម្ងាត់។

## 17.2 ករណីលើកលែង

ពាណិជ្ជករអាចបញ្ចេញព័ត៌មានសម្ងាត់បាន៖

1. ក្នុងវិសាលភាពដែលច្បាប់តម្រូវ ឬ

2. ប្រសិនមានការតម្រូវពាក់ព័ន្ធនឹងដំណើរការនីតិវិធីផ្លូវច្បាប់ពាក់ព័ន្ធនឹងសេវាពាណិជ្ជករ ប៉ុន្តែក្នុងករណីនីមួយៗត្រូវផ្តល់ការជូនដំណឹងគ្រប់គ្រាន់ដល់ធនាគារ អំពីការបញ្ចេញព័ត៌មានដែលបានស្នើឡើង ដើម្បីអាចឱ្យធនាគារអាចស្នើសុំដីកាការពារ ឬដំណោះស្រាយផ្សេងៗ ដើម្បីការពារការបញ្ចេញព័ត៌មាននោះ។



## 17.3 ការប្រគល់ព័ត៌មានសម្ងាត់ត្រលប់មកវិញ

នៅពេលបញ្ចប់ ឬផុតសុពលភាពសេវាពាណិជ្ជករ ឬលឿនជាងនេះទៅតាមការស្នើសុំសមហេតុផលពីធនាគារ ពាណិជ្ជករ ត្រូវតែប្រគល់ជូនធនាគារវិញភ្លាមៗ ឬបំផ្លាញចោលនូវរាល់ច្បាប់ចម្លងនៃព័ត៌មានសម្ងាត់ទាំងអស់ ដែលក្នុងករណីនេះសិទ្ធិប្រើប្រាស់ ចម្លង និងការបញ្ចេញព័ត៌មានសម្ងាត់នឹងត្រូវលុបចោល។

## 17.4 ការបន្តមានសុពលភាពនៃកាតព្វកិច្ច

កាតព្វកិច្ចរបស់ពាណិជ្ជករក្រោមប្រការនេះ នឹងនៅបន្តមានសុពលភាពជារៀងរហូតពាក់ព័ន្ធនឹងព័ត៌មានសម្ងាត់នេះ ទោះបីជាព័ត៌មានសម្ងាត់នេះបានប្រគល់មកឱ្យធនាគារវិញ ឬបានបំផ្លាញចោល ឬខចែង និងលក្ខខណ្ឌនេះផុតសុពលភាពកំណត់ ឬសេវាពាណិជ្ជករត្រូវបានបញ្ឈប់ក្តី។

# 18. ច្បាប់គ្រប់គ្រង និងដែនយុត្តាធិការ

## 18.1 ច្បាប់គ្រប់គ្រង

ខចែង និងលក្ខខណ្ឌ ព្រមទាំងប្រតិបត្តិការដែលមានចែងក្នុងឯកសារនេះ ត្រូវគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## 18.2 ការដាក់ពាក្យប្តឹងទៅតុលាការមានសមត្ថកិច្ច

ភាគីនីមួយៗត្រូវដាក់ពាក្យប្តឹងទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជាដោយដោយគ្មានលក្ខខណ្ឌ ដើម្បីធ្វើការដោះស្រាយវិវាទពាក់ព័ន្ធនឹងខចែង និងលក្ខខណ្ឌនៃប្រតិបត្តិការដែលមានចែងដោយខចែង និងលក្ខខណ្ឌ។ ភាគីនីមួយៗ សូមលះបង់សិទ្ធិដែលខ្លួនមាន ក្នុងការបដិសេធទៅលើសកម្មភាពដែលបានលើកយកទៅដោះស្រាយនៅតុលាការ អះអាងថាសកម្មភាពនោះត្រូវបានដោះស្រាយនៅក្នុងវេទិកាមួយដែលមិនមានភាពងាយស្រួល ឬអះអាងថាតុលាការនោះមិនមានយុត្តាធិការ។

# 19. ហត្ថលេខា

មានតែម្ចាស់ពាណិជ្ជកម្ម ឬបុគ្គលមានសិទ្ធិ ឬអ្នកតំណាងមានសិទ្ធិតែប៉ុណ្ណោះ ដែលអាចចុះហត្ថលេខាលើខចែង និងលក្ខខណ្ឌ ឬកិច្ចព្រមព្រៀងហ្វាស៊ីលីធីពាណិជ្ជករបាន។ នៅពេលចុះហត្ថលេខា ហត្ថលេខី នឹងត្រូវបានភ្ជាប់កាតព្វកិច្ចលើខចែង និងលក្ខខណ្ឌនេះ ហើយកាតព្វកិច្ចរបស់ពួកគេនឹងត្រូវមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

# 20. សេចក្តីសម្រេចជាស្ថាពរ

នៅថ្ងៃចុះហត្ថលេខាលើពាក្យស្នើសុំសម្រាប់ពាណិជ្ជករនេះ ពាណិជ្ជករទទួលស្គាល់ថាធនាគារបានទទួលសិទ្ធិ នឹងត្រូវជូនដំណឹងដល់ពាណិជ្ជករនាពេលអនាគតតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ។

តាមរយៈការចុះហត្ថលេខា ខ្ញុំសូមបញ្ជាក់ទទួលស្គាល់ថាខ្ញុំពិតជាបានអាន យល់ដឹង និងទទួលយកទាំងស្រុងទៅលើខចែង និងលក្ខខណ្ឌនៃហ្វាស៊ីលីធីពាណិជ្ជករនេះ (ខចែង និងលក្ខខណ្ឌ) ដែលមានចែងក្នុងឯកសារនេះ។

# 21. ភាសា

ខចែង និងលក្ខខណ្ឌនេះត្រូវបានធ្វើឡើងជា ពីរ (02) ភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ។ ក្នុងករណីដែលមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ភាសាអង់គ្លេសត្រូវយកជាផ្លូវការ។

## កំណត់ត្រា

**BRED BANK**
CAMBODIA

The smarter
way to bank.

**BRED Bank (Cambodia) Plc.** | Registration: 00002982 | Postal Code: 12210
Head Office: No. 30, Preah Norodom Boulevard, Sangkat Phsar Thmey 3, Khan Daun Penh, Phnom Penh, Cambodia.
Freephone: 1800 20 1234 | International: +855 23 999 222